# វិធីដាំគូលែន

## ១.ការរៀបចំរណ្តៅ:

- ត្រូវជីករណ្តៅ៦តឹកបួនជ្រុង និង ជំរៅ៦តឹក




- រោយកំបោរសប្រមាណ២ស្លាបព្រាបាយក្នុងរណ្តៅ
- ត្រូវដាក់ផេះឬអង្កាម,កំប្លោក,ចំបើងពុក,អាចម៍មាន់ឬអាចម៍ជ្រូកឬអាចម៍គោមួយស្រទាប់កំរាស់១តឹករួចដាក់ដីពីលើ១តឹកធ្វើយ៉ាងនេះរហូតទាល់តែពេញរណ្តៅ ។




- ត្រូវទុករណ្តៅរៀបចំហើយក្នុងរយៈពេល២ ទៅ ៣ អាទិត្យ ។
- ចំងាយពីរណ្តៅមួយទៅរណ្តៅមួយមានប្រវែង ៨ ម៉ែត្រ ។

## ២.ការដាំ:

- កូនគូលែនត្រូវរក្សាផ្សាំទុក១អាទិត្យមុនដាំ
- ផ្អាកស្រោចទឹក២ថ្ងៃមុនដាំដើម្បីកុំអោយបែកដីនិងឫស ។
- មុនដាំត្រូវជញ្ជូនកូនគូលែនដាក់ក្បែររណ្តៅទាំងអស់ ។
- ត្រូវបកថង់ចេញធ្វើយ៉ាងណាកុំអោយបែកដី
- កប់កូនគូលែនក្នុងរណ្តៅដោយធ្វើយ៉ាងណាអោយដីកន្ទោងកូនគូលែនស្មើមាត់រណ្តៅរួចយកមែកឈើដោតក្បែររណ្តៅចងទប់ជាមួយកូនគូលែន ។
- លប់ដីបន្តិចម្តងៗដោយសង្កត់ថ្នមៗហាម សង្កត់លើដីកន្ទោងកូនគូលែនដែលបណ្តាលអោយដាច់ឫស ។



## ៣.ការថែទាំនិងដាក់ជី:

- ខែវស្សារត្រូវពូនគល់ការពារទឹកជាំនៅគល់បណ្តាលអោយរលួយឫស ។
- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉នដោយប្រើជីអាចម៍មាន់ឬអាចម៍ជ្រូកឬអាចម៍គោលាយជាមួយអង្កាមពុក,ចំបើងឬកំប្លោករលួយកាយកប់ក្នុងដីធ្វើជាកំពែង ។
- ប្រសិនបើកូនគូលែនមានសត្វល្អិតស៊ីត្រួយត្រូវប្រើថ្នាំសំលាប់សត្វល្អិត(ណាតូ) ។

